# ២ - ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ២៧៨ អយក.ប្រក**

**ប្រកាស**

**ស្តីពីការពង្រីក អនុវិទ្យាល័យស្ទោង ទៅជា**

**វិទ្យាល័យស្ទោង ក្នុងស្រុកស្ទោង ខេត្តកំពង់ធំ**

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញក្រឹត្យ_ច្បាប់លេខ ៣០ ក្រច. ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៦ ស្តីពីប្រព័ន្ធអប់ រំចំនេះទូទៅ
- យោងលិខិតរបស់ប្រធានមន្ទីរអប់រំ យុវជន និង កីឡា លេខ ៩០២ អកធ.មស ចុះថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ១៩៩៥ ដោយមានយោបល់ឯកភាពពី អភិបាលខេត្តកំពង់ធំ
- តាមសំណើរបស់នាយកដ្ឋានចំនេះទូទៅនិង មធ្យមសិក្សា

**សំរេច**

**ប្រការ ១** : អនុញ្ញាតអោយពង្រីកអនុវិទ្យាល័យស្ទោង ទៅជា " **វិទ្យាល័យស្ទោង** " ចាប់ពីឆ្នាំសិក្សា ១៩៩៥_៩៦ តទៅ នៅក្នុងស្រុកស្ទោង ខេត្តកំពង់ធំ ។

**ប្រការ ២** : វិទ្យាល័យ ស្ពោង ត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំង បុគ្គលិកផ្សេងៗទៀតមួយចំនួន តាមអង្គការលេខនៃវិទ្យាល័យ ។

**ប្រការ ៣** : នាយក_នាយករង នៃវិទ្យាល័យ មានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់ នាយក នាយករង នៃវិទ្យាល័យ ។

**ប្រការ ៤**: បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥** : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានចំណេះទូទៅ និង មត្តេយ្យសិក្សា ប្រធាននាយកដ្ឋានបុគ្គលិក ប្រធាននាយកដ្ឋានផែនការ និងហិរញ្ញកិច្ច នៃក្រសួងអប់រំ យុវជន និងកីឡា ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ធំ នាយកវិទ្យាល័យស្ពោង មានភារកិច្ចរៀងៗ ខ្លួនអនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

**ហត្ថលេខា និង ត្រា**

**តុល ឡោះ**

* * *

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ១៩៩៦

**ប្រកាសលេខ ២៨៤ អយក.ប្រក**

**ប្រកាស**

**ស្តីពីការប្តូរឈ្មោះ សាលាបឋមសិក្សា ទឹកឃ្លាំង**

* * *

រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ត[illegible] តែងតាំង រាជរដ្ឋាភិបាល
- បានឃើញច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤